# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សេចក្តីព្រាងអនុក្រឹត្យស្តីពីការកម្រិតរបបម៉ោងកំណត់
# ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម
# ក្រសួងអប់រំ យុវជន និងកីឡា

លេខយោង:

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦

កាលបរិច្ឆេទបញ្ចប់: ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

បញ្ញត្តិកម្មនេះត្រូវបានស្នើឡើង ដើម្បីកែសម្រួលរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម ដែលកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ន សម្រាប់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ ឬអ្នកឯកទេសផ្សេងទៀត ដែលបង្រៀន និងបំពេញការងារគរុកោសល្យ ព្រមទាំងបំពេញការងារដែលពាក់ព័ន្ធនឹងការបង្រៀននៅក្នុងវិស័យអប់រំ និងអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀន និងរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ស្របតាមអាទិភាពកំណត់ដោយរាជរដ្ឋាភិបាល និងស្របតាមលទ្ធភាពនៃថវិកា ក្នុងគោលដៅពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀននិងរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងលើកទឹកចិត្តដល់បុគ្គលិកអប់រំដែលបង្រៀនលើសពីរបបម៉ោងកំណត់។

បញ្ញត្តិកម្មនេះមានវិសាលភាពអនុវត្ត ចំពោះគ្រប់គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ដែលស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ស្តីពីការអប់រំ។

របបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម ត្រូវបានអនុវត្តដោយផ្អែកលើសញ្ញាបត្រដែលត្រូវនឹងមុខវិជ្ជាបង្រៀន ក្របខណ្ឌ និងកម្រិតសិក្សាដែលបានបង្រៀន។

ក្រសួង ស្ថាប័ន ដែលមានតម្រូវការប្រើប្រាស់ម៉ោងបន្ថែមនៅតាមគ្រឹះស្ថានសិក្សាសាធារណៈក្រោមឱវាទរបស់ខ្លួន ត្រូវរៀបចំផែនការប្រើប្រាស់ និងថវិការបបម៉ោងបន្ថែមឱ្យបានច្បាស់លាស់ ដើម្បីដាក់ស្នើដល់រាជរដ្ឋាភិបាល សម្រាប់បញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ។ បន្ទាប់ពីបានទទួលការអនុញ្ញាតលើការគ្រោងថវិកាសម្រាប់របបម៉ោងបន្ថែម ក្រសួង ស្ថាប័ន ត្រូវធ្វើការបែងចែក ជូនដំណឹង និងអនុវត្តរបបម៉ោងបន្ថែមស្របតាមឥណទានថវិកាដែលបានកំណត់ ដោយមិនអាចអនុវត្តដោយគ្មានឥណទានថវិកាបានឡើយ។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ នូវផែនការបណ្តុះបណ្តាលប្រចាំឆ្នាំរបស់គ្រឹះស្ថានសិក្សាសាធារណៈ ដែលរួមមានចំនួនសិស្ស និស្សិត ថ្នាក់រៀន គ្រូបង្រៀន ចំនួនមុខវិជ្ជា ចំនួនម៉ោងបង្រៀន។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ លើកំហុសនានាដែលកើតឡើងពីការប្រើប្រាស់របបម៉ោងបន្ថែមក្នុងគ្រឹះស្ថានសិក្សាសាធារណៈរបស់ខ្លួន។

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
| --- | --- | --- | --- | --- | --- | --- |
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ

☐សេដ្ឋកិច្ច ☐សង្គមកិច្ច ☐បរិស្ថាន ☑អប់រំ

## ១. ការកំណត់បញ្ហា

១.ក បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

**១.កង្វះគ្រូបង្រៀន**

កង្វះគ្រូនៅតាមគ្រឹះស្ថានសិក្សា នាំឱ្យមានការអនុញ្ញាតឱ្យគ្រូបង្រៀនទៅបង្រៀននូវមុខវិជ្ជាផ្សេងពីឯកទេសដើមរបស់ខ្លួន ឬបង្រៀនក្នុងកម្រិតសិក្សាដែលមិនឆ្លើយតបទៅនឹងក្របខណ្ឌរបស់ខ្លួន។
ឧទាហរណ៍ទី១៖ គ្រូឯកទេសប្រវត្តិវិទ្យា ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ទៅបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ថ្នាក់ទី១១ (បង្រៀនក្នុងកម្រិតសិក្សាដែលមិនឆ្លើយតបទៅនឹងក្របខណ្ឌរបស់ខ្លួន)។
ឧទាហរណ៍ទី២៖ គ្រូឯកទេសគីមីវិទ្យា ទៅបង្រៀនមុខវិជ្ជាផែនដីវិទ្យា (បង្រៀននូវមុខវិជ្ជាផ្សេងពីឯកទេសដើមរបស់ខ្លួន)។
ឧទាហរណ៍ទី៣៖ ឆ្លើយតបទៅនឹងបរិបទនៃការអភិវឌ្ឍរបស់អាស៊ាន និងពិភពលោក និងឆ្លើយតបទៅនឹងធម្មនុញ្ញរបស់អាស៊ានត្រង់មាត្រា៣៤ ដែលបានកំណត់យកភាសាអង់គ្លេស ជាភាសាប្រើប្រាស់ផ្លូវការរបស់អាស៊ាន ក្រសួងបានអភិវឌ្ឍកម្មវិធីសិក្សាដោយដាក់បញ្ចូលភាសាបរទេសទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សាចាប់ពីកម្រិតថ្នាក់ទី៤។ ប៉ុន្តែ សមត្ថភាពរបស់គ្រូបង្រៀនបឋមសិក្សាដែលមានស្រាប់មិនទាន់ឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីសិក្សាថ្មីនេះ ជាហេតុធ្វើឱ្យមានតម្រូវការគ្រូបង្រៀនភាសាបរទេសនៅថ្នាក់បឋមសិក្សា ។ ដូចនេះ ក្រសួងបានសម្រេចអនុញ្ញាតឱ្យគ្រូមធ្យមសិក្សាអាចបង្រៀនឆ្លងភូមិសិក្សាបាន ដែលនេះ គឺជាការអនុវត្តនូវគោលការណ៍ដែលមានចែងនៅក្នុងអនុក្រឹត្យចាស់ ដើម្បីបំពេញតម្រូវការបញ្ហាកង្វះគ្រូបង្រៀន។

**២.ប្រាក់ម៉ោងបន្ថែមបច្ចុប្បន្នមានកម្រិតទាប**

ផ្អែកលើអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ប្រាក់ម៉ោងបន្ថែមរបស់គ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅមធ្យមសិក្សាបឋមភូមិទទួលបាន ២៦០០ រៀល ក្នុងមួយម៉ោង គ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅមធ្យមសិក្សាទុតិយភូមិទទួលបាន ៥២០០រៀល ក្នុងមួយម៉ោង និងគ្រូបង្រៀនកម្រិតឧត្តមបង្រៀននៅឧត្តមសិក្សាទទួលបាន ៩៣០០ រៀល ក្នុងមួយម៉ោង ដែលកម្រៃនេះមានកម្រិតទាប ធៀបទៅនឹងស្ថានភាពនៃការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន។ ដោយប្រាក់

ម៉ោងបន្ថែមមានចំនួនតិចតួច បើធៀបជាមួយប្រាក់ម៉ោងនៃគ្រឹះស្ថានសិក្សាឯកជន ជាហេតុធ្វើឱ្យគ្រូបង្រៀនមិនសូវមានឆន្ទៈក្នុងការបំពេញ ឬទទួលយកនូវម៉ោងបន្ថែមពីគ្រឹះស្ថានសាធារណៈ ដោយឆ្លៀតយកពេលសេសសល់ពីការបំពេញកាតព្វកិច្ចនៅក្នុងអង្គភាពរបស់ខ្លួន ទៅបង្រៀននៅគ្រឹះស្ថានសិក្សាឯកជន ដើម្បីទទួលបានប្រាក់កម្រៃបន្ថែម។

**៣.ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង**

ដោយសារកង្វះគ្រូបង្រៀន ធ្វើឱ្យគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាមានការលំបាកក្នុងការធានាផ្តល់សេវាអប់រំដល់អ្នកសិក្សា និងលំបាកក្នុងការធានាគុណភាពអប់រំឱ្យបានឆ្លើយតបទៅនឹងចក្ខុវិស័យ និងគោលនយោបាយរបស់ក្រសួង។ ដោយសារតែ ប្រាក់ម៉ោងបន្ថែមមានកម្រិតទាប ធ្វើឱ្យគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា មានការលំបាកក្នុងការជំរុញគ្រូបង្រៀនឱ្យទទួលបង្រៀនម៉ោងបន្ថែម។ ដូច្នេះហើយ បន្ទុកនៃការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើគ្រឹះស្ថានសិក្សាក្រោមឱវាទរបស់ខ្លួន ពុំសូវបានពេញលេញ។

១.៥ បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង(ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

**១.កាត់បន្ថយការស្នើសុំភាពទំនេរគ្មានបៀវត្ស**

បើប្រៀបធៀបប្រាក់កម្រៃម៉ោងបន្ថែមនៃសំណើបញ្ញត្តិកម្មថ្មីនេះ ជាមួយនឹងប្រាក់កម្រៃនៅតាមគ្រឹះស្ថានសិក្សាឯកជនបច្ចុប្បន្នឃើញថាប្រហាក់ប្រហែលគ្នា ដែលកន្លងមក ប្រាក់ម៉ោងបន្ថែមនៅក្នុងអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ មានតម្លៃតិចតួច ជាហេតុធ្វើគ្រូមួយចំនួនធ្វើការស្នើសុំភាពទំនេរគ្មានបៀវត្ស ដើម្បីទៅបង្រៀននៅគ្រឹះស្ថានសិក្សាឯកជន ឬទៅបម្រើការងារនៅកន្លែងផ្សេងទៀត។

**២.កាត់បន្ថយការផ្លាស់ប្តូរទីកន្លែងបម្រើការងារ**

កន្លងមក គ្រូបង្រៀនតែងតែមានតម្រូវការក្នុងការផ្លាស់ប្តូរទីកន្លែងបម្រើការងារទៅទីប្រជុំជន ឬទីក្រុង ដើម្បីមានឱកាសក្នុងការបង្រៀនគួរក្រៅម៉ោងស្វែងរកប្រាក់កម្រៃក្រៅ និងឆ្លៀតប្រកបរបររកទទួលទានបន្ថែមលើមុខរបរជាគ្រូបង្រៀន ដែលធ្វើឱ្យគ្រូនៅតាមគ្រឹះស្ថានសិក្សាសាធារណៈនៅទីប្រជុំជន មានចំនួនលើស និងធ្វើឱ្យខ្វះគ្រូនៅទីជនបទ ឬតំបន់ដាច់ស្រយាល។ បន្ទាប់ពីបញ្ញតិកម្មនេះត្រូវបានដាក់ឱ្យប្រើប្រាស់ ការស្នើសុំផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់គ្រូបង្រៀននឹងត្រូវបានកាត់បន្ថយ ព្រោះប្រាក់កម្រៃម៉ោងបន្ថែម គឺប្រហាក់ប្រហែលទៅនឹងគ្រឹះស្ថានសិក្សាឯកជន ដែលធ្វើឱ្យគាត់មានទឹកចិត្តជាងមុន ក្នុងការបំពេញការងារនៅអង្គភាពដើម ដើម្បីទទួលបាននូវចំនួនម៉ោងបន្ថែមឱ្យបានច្រើន និងប្រាក់កម្រៃម៉ោងបន្ថែមបានច្រើន។

**៣.កាត់បន្ថយភាពខ្វះចន្លោះក្នុងការបំពេញកាតព្វកិច្ច**

ដោយសារប្រាក់បង្រៀនក្នុងរបបម៉ោងបន្ថែមមានកម្រៃតិច គ្រូមួយចំនួនពុំសូវរំពឹងប្រាក់កម្រៃពីការបង្រៀនលើសម៉ោងឡើយ និងពេលខ្លះពុំសូវយកចិត្តទុកដាក់ក្នុងការបង្រៀនរបបម៉ោងកំណត់ដែលជាកាតព្វកិច្ចរបស់ខ្លួនឡើយ ដោយសារតែគ្រូបង្រៀនមួយចំនួនឆ្លៀតទៅរកទទួលទាននៅខាងក្រៅ។ ប្រសិន ប្រាក់ម៉ោងបន្ថែមបានប្រាក់កម្រៃបានច្រើន ជួយជំរុញនិងលើកទឹកចិត្តគ្រូបង្រៀន ឱ្យមានឆន្ទៈក្នុងការបំពេញការងារក្នុងអង្គភាពរបស់ខ្លួន ជាជាងការឆ្លៀតពេលទៅបង្រៀននៅគ្រឹះស្ថានសិក្សាឯកជន។

**៩.ចូលរួមពង្រឹងយន្តការពង្រាយគ្រូបង្រៀន**

ប្រសិនប្រាក់កម្រៃម៉ោងបន្ថែមមានតម្លៃសមស្របទៅនឹងស្ថានភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងប្រហាក់ប្រហែលទៅនឹងកម្រៃនៃគ្រឹះស្ថានសិក្សាឯកជន គ្រូបង្រៀនមួយចំនួននឹងមានឆន្ទៈទទួលយកនូវទីកន្លែងធ្វើការតាមការចាត់តាំង មិនថានៅតំបន់ទីជនបទ និងតំបន់ដាច់ស្រយាល។ ប្រការនេះ ជួយលើកកម្ពស់ការអនុវត្តនូវគោលនយោបាយពង្រាយគ្រូបង្រៀនឱ្យមានប្រសិទ្ធភាព។

១.គ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះ មិនទាន់គ្រប់គ្រាន់?

- អនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម សម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ «ប្រាក់ម៉ោងបន្ថែមមានចំនួនទឹកប្រាក់ពី ២៦០០រៀល-៥២០០រៀល សម្រាប់មធ្យមសិក្សា និង ៩៣០០រៀល-១០៩០០រៀល សម្រាប់ឧត្តមសិក្សា»
- អនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា ត្រង់មាត្រា៥ បានចែងថា «មន្ត្រីរាជការស៊ីវិលត្រូវអនុវត្តកាតព្វកិច្ចការងាររយៈពេល៨ (ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ និង៥ (ប្រាំ) ថ្ងៃ ក្នុងមួយសប្តាហ៍ ឬរយៈពេល៤០ (សែសិប) ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីធានាឱ្យបាននូវនិរន្តរភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងស្ថាប័ន និងអង្គភាព»
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤ គឺគ្រាន់តែជាច្បាប់ទូទៅ ដែលចែងអំពីបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ ត្រង់មាត្រា២១ ចែងថា «រដ្ឋលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្តីត្រូវការខាងសិក្សាមូលដ្ឋាន និងជំនាញសម្រាប់ឱ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមអភិវឌ្ឍប្រទេស»
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម «បានចែងពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច ប៉ុន្តែមិនបានចែងពីថវិកាទាក់ទងនឹងការបង្រៀនឡើយ»

- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន«បានចែងពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច ប៉ុន្តែមិនបានចែងពីថវិកាទាក់ទងនឹងការបង្រៀនឡើយ»
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៨១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម «បានចែងពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ច ប៉ុន្តែមិនបានចែងពីថវិកាទាក់ទងនឹងការបង្រៀនឡើយ»
- អនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនត្រង់មាត្រា៨ បានចែងថា «គ្រូបង្រៀនប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ មានករណីយកិច្ចរៀបចំកិច្ចតែងការបង្រៀន និងកំណត់ការពន្យល់សំដៅធានាគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន»

លិខិតបទដ្ឋានទាំងអស់ខាងលើ បានកំណត់អំពីតួនាទី ភារកិច្ច និងកាតព្វកិច្ចដែលគ្រូបង្រៀនត្រូវបំពេញ ឬអនុវត្ត ប៉ុន្តែលិខិតបទដ្ឋានទាំងនេះ មិនបានកំណត់អំពីកម្រៃដែលគ្រូបង្រៀនត្រូវទទួលបាននៅពេលបំពេញការងារលើសពីចំនួនម៉ោងកំណត់នោះឡើយ។ មានតែអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ មួយគត់ ដែលបានកំណត់ពីកម្រៃប្រាក់ម៉ោងបន្ថែម ប៉ុន្តែប្រាក់កម្រៃម៉ោងបន្ថែមនេះមានកម្រិតទាប មិនបានឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្នឡើយ។

១.ឃ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? (ប្រសិនបើមានសូមពន្យល់)

សំណើបញ្ញត្តិកម្មនេះ មានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងជាមួយគ្រឹះស្ថានសិក្សាឯកជនដូចខាងក្រោម ៖

សំណើបញ្ញត្តិកម្មនេះអាចនឹងមានផលប៉ះពាល់អវិជ្ជមានខ្លះៗដល់គ្រឹះស្ថានសិក្សាឯកជន ដោយហេតុថា គម្រោងកំណត់ប្រាក់ម៉ោងបន្ថែមថ្មីនេះ នឹងមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃម៉ោងបង្រៀននៅតាមគ្រឹះស្ថានសិក្សាឯកជន ដែលជាកត្តាជំរុញឱ្យគ្រូដែលធ្លាប់ចេញទៅបម្រើការនៅតាមគ្រឹះស្ថានឯកជន នឹងប្តូរមកបំពេញការងារពេញលេញនៅក្នុងអង្គភាពរបស់ខ្លួនវិញ និងធ្វើឱ្យគុណភាពអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈកាន់មានភាពប្រសើរឡើងវិញ។ ប្រការនេះ នឹងធ្វើឱ្យសិស្សងាកមកទទួលយកសេវាអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈវិញ ព្រោះអ្នកអាណាព្យាបាលសិស្សចំណាយអស់តិចក្នុងការផ្គត់ផ្គង់ការសិក្សាកូន។ ដូច្នេះ គ្រឹះស្ថានសិក្សាឯកជនមួយចំនួនអាចនឹងមានបញ្ហាប្រឈមកង្វះគ្រូបង្រៀន។ ដូចនេះ គ្រឹះស្ថានសិក្សាឯកជនមួយចំនួន អាចនឹងតំឡើងថ្លៃសិក្សាដើម្បីឱ្យខ្លួនអាចតំឡើងប្រាក់ម៉ោងបង្រៀនរបស់ខ្លួនបាន ដែលប្រការនេះ អាចជះឥទ្ធិពលទៅបន្ទុកចំណាយរបស់អ្នកអាណាព្យាបាលសិស្សដែលបញ្ជូនកូនមករៀននៅគ្រឹះស្ថានសិក្សាឯកជន។

យ៉ាងណាមិញ បើទោះបីជាសំណើបញ្ញត្តិកម្មនេះ មានផលប៉ះពាល់អវិជ្ជមានដល់គ្រឹះស្ថានសិក្សាឯកជនក្តី ប៉ុន្តែមានផលប៉ះពាល់ខ្លាំងត្រឹមតែគ្រឹះស្ថានសិក្សាឯកជនដែលស្ថិតនៅក្រៅទីប្រជុំជន

| |
|---|
| ទេ ព្រោះគ្រឹះស្ថានសិក្សាឯកជននៅទីប្រជុំជន សាលាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការតំឡើងប្រាក់កម្រៃគ្រូបង្រៀន ចំណែកអ្នកអាណាព្យាបាលសិស្សវិញ ក៏មានលទ្ធភាពគ្រប់គ្រាន់ដើម្បីបង់ថ្លៃសិក្សារបស់កូនដែរ ប៉ុន្តែសម្រាប់គ្រឹះស្ថានសិក្សាឯកជននៅក្រៅទីប្រជុំជន ពុំសូវមានលទ្ធភាពទេ ដោយហេតុថាសិស្សមានចំនួនតិច ហើយកម្រិតជីវភាពអ្នកអាណាព្យាបាលសិស្សនៅមានកម្រិតនៅឡើយ។ លើសពីនេះ បើទោះបីជាមានផលប៉ះពាល់អវិជ្ជមានដល់គ្រឹះស្ថានសិក្សាឯកជនយ៉ាងណាក្តី តែមានផលចំណេញច្រើនដល់គុណភាពអប់រំនៅគ្រឹះស្ថានសិក្សាសាធារណៈ ជាពិសេសជួយលើកស្ទួយកម្រិតជីវភាពរបស់គ្រូបង្រៀន។ |

## ២. **គោលបំណង** តើយើងចង់សម្រេចបានអ្វី?

| |
|---|
| សេចក្តីព្រាងអនុក្រឹត្យនេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីបង្កើនប្រាក់កម្រៃម៉ោងបន្ថែមជូនដល់គ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយចូលរួមដោះស្រាយ នូវបញ្ហាកង្វះគ្រូបង្រៀន និងជួយថែរក្សាគ្រូបង្រៀន ឱ្យស្ថិតនៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ សំដៅចូលរួមធានាគុណភាព និងប្រសិទ្ធិភាពនៃការអប់រំ។ |

## ៣. ជម្រើស

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១.បន្តអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៨៦<br>២.សំណើអនុក្រឹត្យថ្មីតែអនុវត្តត្រឹមក្រសួងអប់រំ យុវជន និងកីឡា<br>៣.សំណើអនុក្រឹត្យថ្មីតែអនុវត្តគ្រប់ក្រសួង ស្ថាប័នទាំងអស់ |

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពូកិច្ច និងផលចំណេញ

៤.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ១៩៨៦ | - បន្ទុកចំណាយលើការផ្តល់ម៉ោងបន្ថែម | គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងអនុក្រឹត្យថ្មី តែអនុវត្តសម្រាប់តែគ្រឹះស្ថានសិក្សាដែលស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា | - បន្ទុកចំណាយលើការរៀបចំសេចក្តីព្រាងអនុក្រឹត្យថ្មី ប្រហែល ១៥,២៥៤,៤៤៤ រៀល (ស្មើនឹង ៣,៨១៤ $) | - សេវាឯកជនវិស័យអប់រំ ត្រូវបង្កើនបន្ទុកចំណាយលើប្រាក់ម៉ោង និងប្រាក់បៀវត្សដល់បុគ្គលិក |

| | | |
|---|---|---|
| | - បន្ទុកចំណាយលើការផ្សព្វផ្សាយ ២៥ រាជធានី ខេត្ត ប្រហែល ៨,៥២៩,៨១៤,២០០ រៀល (ស្មើនឹង ២,១៣២,៣៥៣.៥៥$)<br>- បង្កើនបន្ទុកចំណាយលើប្រាក់ម៉ោងបន្ថែមប្រហែលចំនួន ១៧,២៨២,៤៧៣,៤០០រៀល (ស្មើនឹង ៤,៣១៦,០១២ដុល្លា) | - បង្កើនបន្ទុកចំណាយរបស់អាណាព្យាបាលសិស្សក្នុងការបង់ថ្លៃសិក្សា |
| ជម្រើសទី៣៖ សេចក្តីព្រាងអនុក្រឹត្យថ្មី តែអនុវត្តគ្រប់ក្រសួង ស្ថាប័នទាំងអស់ | ពុំអាចធ្វើការគណនាបាន ដោយហេតុថា ពិបាកក្នុងការស្នើសុំទិន្នន័យពី ក្រសួង ស្ថាប័នពាក់ព័ន្ធ | - សេវាឯកជនវិស័យអប់រំ ត្រូវបង្កើនបន្ទុកចំណាយលើប្រាក់ម៉ោង និងប្រាក់បៀវត្សដល់បុគ្គលិក<br>- បង្កើនបន្ទុកចំណាយរបស់អាណាព្យាបាលសិស្សក្នុងការបង់ថ្លៃសិក្សា |

៤.២ ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ | - រក្សាស្ថានភាពដើម។<br>- ផលចំណេញបានតិចតួចពីរបបប្រាក់ម៉ោងបន្ថែម | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងអនុក្រឹត្យថ្មី តែអនុវត្តសម្រាប់តែគ្រឹះស្ថានសិក្សាដែលស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា | - បានបង្ហាញនូវការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ ជាពិសេសការលើកកម្ពស់កម្រិតជីវភាពបុគ្គលិកអប់រំ<br>- បុគ្គលិកអប់រំមានឆន្ទៈ មនសិការវិជ្ជាជីវៈ ក្នុងការប្រកបរបរជាគ្រូបង្រៀន | - គ្មាន |

| | | |
|---|---|---|
| | - ជំរុញការប្រើប្រាស់បុគ្គលិកអប់រំដែលមានស្រាប់អស់លទ្ធភាព<br>- ផ្ដល់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន<br>- អាចជួយកាត់បន្ថយកង្វះគ្រូបង្រៀននៅតាមជនបទ<br>- លើកកម្ពស់ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង | |
| ជម្រើសទី៣៖ សេចក្ដីព្រាងអនុក្រឹត្យថ្មី តែអនុវត្តគ្រប់ក្រសួងស្ថាប័នទាំងអស់ | - បានបង្ហាញនូវការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ ជាពិសេសការលើកកម្ពស់កម្រិតជីវភាពបុគ្គលិកអប់រំ<br>- បុគ្គលិកអប់រំមានឆន្ទៈមនសិការវិជ្ជាជីវៈ ក្នុងការប្រកបរបរជាគ្រូបង្រៀន<br>- ជំរុញការប្រើប្រាស់បុគ្គលិកអប់រំដែលមានស្រាប់អស់លទ្ធភាព<br>- ផ្ដល់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន<br>- អាចជួយកាត់បន្ថយកង្វះគ្រូបង្រៀននៅតាមជនបទ<br>- លើកកម្ពស់ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង | - គ្មាន |

៤.៣ វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តអនុក្រឹត្យ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ១៩៩៦និងសេចក្ដីណែនាំលេខ៣៣អយក.សណន | គ្មាន | គ្មាន | |

| | | | |
|---|---|---|---|
| ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៤ ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ | | | |
| ជម្រើសទី២៖ សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែម | គ្រឹះស្ថានសិក្សាឯកជន | ចំនួនសាលាឯកជន (៧៣៧សាលា) ប៉ុន្តែយើងពុំអាចដឹងថាចំនួនគ្រឹះស្ថានសិក្សាឯកជនដែលទាញយកចំនួន គ្រូ និងសាស្ត្រាចារ្យពីគ្រឹះស្ថានសិក្សាសាធារណៈមានចំនួនប៉ុន្មាននោះទេ | សន្និបាតអប់រំ ឆ្នាំ២០១៤-២០១៥ |
| ជម្រើសទី៣៖ សេចក្ដីព្រាងអនុក្រឹត្យថ្មី តែអនុវត្តគ្រប់ក្រសួង ស្ថាប័នទាំងអស់ | គ្រឹះស្ថានសិក្សាឯកជន | ចំនួនសាលាឯកជន ៧៥០ (ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ៧៣៧ សាលា និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈចំនួន ១៣ សាលា) | សន្និបាតអប់រំ ឆ្នាំ២០១៤-២០១៥ |

## ៥. កិច្ចពិគ្រោះយោបល់

បានធ្វើការពិគ្រោះយោបល់ជាមួយគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៦. សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

| |
|---|
| បញ្ញត្តិកម្មដែលស្នើឡើងនេះ មានផលប៉ះពាល់ដល់ធុរកិច្ចប៉ុន្តែបញ្ញត្តិកម្មនេះនឹងផ្ដល់នូវផលវិជ្ជមានសម្រាប់វិស័យអប់រំសាធារណៈ ដូច្នេះជម្រើសទី២ គួរត្រូវបានជ្រើសរើស។ |

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

៧.១តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

| |
|---|
| បើសិនជាសំណើរៀបចំអនុក្រឹត្យថ្មីនេះត្រូវបានជ្រើសរើស វិធានការដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលប្រតិបត្តិ គឺត្រូវប្រាកដថា មានការផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យនេះឱ្យបានទូលំទូលាយ មានការបែងចែង និងអនុវត្តរបបម៉ោងបន្ថែមមានភាពត្រឹមត្រូវច្បាស់លាស់។ លើសពីនេះ ត្រូវមានយន្តការតាមដានការទទួលខុសត្រូវលើគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាលើការរៀបចំ និងអនុវត្តរបបម៉ោងបន្ថែម។ |

៧.២តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញ/តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| |
|---|
| ក្នុងករណីសំណើអនុក្រឹត្យថ្មីត្រូវបានជ្រើសរើស អនុក្រឹត្យថ្មីនេះគួរត្រូវបានពិនិត្យឡើងវិញរៀងរាល់៥ឆ្នាំម្តង។ |

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា (ក្រុមការងារRIA របស់ក្រសួង និងការិ.វាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋាន | ឯឧ. ស៊ន សេងហុក | ប្រធាន RIA | | | |
| | លោក ប៉ូវ វី | អនុប្រធាន RIA | | | |
| | ល.ស ខូវ សោភ័ណ | សមាជិក និងជាប្រធានការិ.វ.ផ.ល | | | |
| | លោក រស់ ស៊ីផាន់ | អនុប្រធានការិ.វ.ផ.ល | | | |
| | លោក សៅ បូរិន | បុគ្គលិកអប់រំការិ.វ.ផ.ល | | | |
| | លោក ស៊ាន បញ្ញា | សមាជិក RIA | | | |
| | លោក គូ សុផាត | បុគ្គលិកអប់រំការិ.វ.ផ.ល | | | |
| ត្រួតពិនិត្យដោយ | ល.ជ ស៊ាង សុផល្លា | | | | |
| ឯកភាពដោយ | ឯឧ. ប៉ិច សុខា | | | | |